# ធនាគារ ព្រីនស៍ ម.ក

## បញ្ញត្តិ និងលក្ខខណ្ឌសម្រាប់កម្មវិធីលើកទឹកចិត្ត លើការដាក់ប្រាក់បញ្ញើមានកាលកំណត់ដោយទទួលបានការប្រាក់ជាមុន ជាមួយ ធនាគារ ព្រីនស៍

ធនាគារ ព្រីនស៍ ម.ក ("**ធនាគារ ព្រីនស៍**") កំពុងដាក់ដំណើរការកម្មវិធីលើកទឹកចិត្តលើការដាក់ប្រាក់បញ្ញើមានកាលកំណត់ដោយទទួលបានការប្រាក់ជាមុន ជាមួយ ធនាគារ ព្រីនស៍ ដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌ ដែលបានចែងនៅទីនេះ ("**កម្មវិធីលើកទឹកចិត្ត**")។ តាមរយៈការចូលរួមកម្មវិធីលើកទឹកចិត្តនេះ អ្នកចូលរួមយល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌដូចខាងក្រោម ព្រមទាំងបញ្ញត្តិ និងលក្ខខណ្ឌទូទៅ បញ្ញត្តិនិងលក្ខខណ្ឌជាក់លាក់សម្រាប់គណនីប្រាក់បញ្ញើមានកាលកំណត់ និងបញ្ញត្តិ និងលក្ខខណ្ឌដែលពាក់ព័ន្ធដទៃទៀត៖

១. រាល់អតិថិជនជារូបវន្តបុគ្គល និងនីតិបុគ្គល ("**អ្នកចូលរួម**") អាចចូលរួមក្នុងកម្មវិធីលើកទឹកចិត្តនេះ ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌដែលមានចែងទីនេះ។

២. អ្នកចូលរួមដែលបានបើកគណនីបញ្ញើមានកាលកំណត់ថ្មី សម្រាប់រយៈពេលបញ្ញើជាក់លាក់ណាមួយ នៅតាមសាខាប្រតិបត្តិការណាមួយរបស់ ធនាគារ ព្រីនស៍ នឹងទទួលបានការផ្តល់ជូននូវអត្រាការប្រាក់ពិសេស ដោយអនុលោមតាមលក្ខខណ្ឌដូចមានចែងខាងក្រោម៖

| ផលិតផល | ទឹកប្រាក់បញ្ញើ និងរយៈពេល | | អត្រាការប្រាក់ផ្តល់ជូន |
|---|---|---|---|
| | ទឹកប្រាក់បញ្ញើអប្បបរមា | រយៈពេល | |
| បើកគណនីបញ្ញើមានកាលកំណត់ថ្មី តាមរយៈសាខាប្រតិបត្តិការណាមួយរបស់ ធនាគារ ព្រីនស៍ (លក្ខខណ្ឌទទួលបានការប្រាក់ជាមុនប៉ុណ្ណោះ) | ១000ដុល្លារអាមេរិក ឬ ៤.000.000 រៀល | ៦ ខែ | ៦% ក្នុងមួយឆ្នាំ ឬ ៦,៥% ក្នុងមួយឆ្នាំ* |
| | | ៨ ខែ | ៦,៨៨% ក្នុងមួយឆ្នាំ |
| | | ៩ ខែ | ៦,៩៩% ក្នុងមួយឆ្នាំ |

**លក្ខខណ្ឌ៖**

- ការផ្តល់ជូននេះ គឺសម្រាប់តែគណនីបញ្ញើមានកាលកំណត់ ដែលត្រូវបានបើក ក្នុងរយៈពេលនៃកម្មវិធីលើកទឹកចិត្ត ដែលគិតចាប់ពី **ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤** ឬនៅពេលមានការជូនដំណឹងពី ធនាគារ ព្រីនស៍ តែប៉ុណ្ណោះ។
- ទឹកប្រាក់បញ្ញើ ត្រូវតែជាប្រាក់បញ្ញើថ្មី (ប្រាក់បញ្ញើថ្មីដែលដាក់ចូលគិតចាប់ពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣)។ ត្រូវអនុវត្តដូចគ្នាចំពោះទឹកប្រាក់បញ្ញើដែលបានមកពីការបិទគណនីបញ្ញើនៅកាលកំណត់ ដោយមានបូកបន្ថែមប្រាក់បញ្ញើថ្មីដែលមានចំនួនយ៉ាងតិច២០%នៃទឹកប្រាក់បញ្ញើសរុប។

- ទឹកប្រាក់បញ្ញើអតិបរមាត្រូវកម្រិតត្រឹមចំនួន ១លានដុល្លាអាមេរិក (ឬចំនួនសមមូលជាប្រាក់រៀល) សម្រាប់អតិថិជនមួយរូបប៉ុណ្ណោះ។
- ការប្រាក់នឹងផ្តល់ជូននៅកាលបរិច្ឆេទបើកគណនីបញ្ញើមានកាលកំណត់។
- លក្ខខណ្ឌដាក់បញ្ញើឡើងវិញ (Rollover) ត្រូវអនុវត្ត (ជាមួយនឹងអត្រាការប្រាក់ទូទៅ)។
- អត្រាការប្រាក់នៅក្រោមកម្មវិធីលើកចិត្តនេះ នឹងត្រូវបានផ្តល់ជូននៅកាលបរិច្ឆេទបើកគណនីមានកាលកំណត់។
- គណនីបញ្ញើមានកាលកំណត់ដែលត្រូវបានបើកនៅក្រោមកម្មវិធីនេះ ត្រូវមានភ្ជាប់លក្ខខណ្ឌបន្តរយៈពេលបញ្ញើដោយស្វ័យប្រវត្តិ ដោយត្រូវអនុវត្តអត្រាការប្រាក់ស្តង់ដាររបស់ ធនាគារ ព្រីនស៍ សម្រាប់រយៈពេលដែលត្រូវបន្ត (Rollover condition with standard interest rate) ។
- អត្ថប្រយោជន៍ដែលមានផ្តល់ជូននៅក្រោមកម្មវិធីនេះ មិនអនុវត្តទន្ទឹមគ្នាជាមួយនឹងអត្ថប្រយោជន៍ឬការផ្តល់ជូននៅក្រោមកម្មវិធីលើកទឹកចិត្ត ឬគម្រោងអត្ថប្រយោជន៍ដទៃទៀតដែលអ្នកចូលរួមមាននោះទេ។

* អត្រាការប្រាក់ចំនួន ៦,៥% ក្នុងមួយឆ្នាំ នឹងត្រូវបានផ្តល់ជូនសម្រាប់តែគណនីបញ្ញើដែលបើកសម្រាប់រយៈពេល៦ខែ ដោយមានទឹកប្រាក់បញ្ញើយ៉ាងតិចចំនួន ១២០.០០០ ដុល្លារអាមេរិក (ឬចំនួនសមមូលជាប្រាក់រៀល) ហើយអ្នកចូលរួមត្រូវតែបើកគណនីសន្សំឆ្លាតវៃជាមួយ ធនាគារ ព្រីនស៍ យ៉ាងតិច១គណនី។

៣. អ្នកចូលរួម យល់ព្រមថា ធនាគារ ព្រីនស៍ រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល ឬបុគ្គលិករបស់ធនាគារ ព្រីនស៍ មិនត្រូវទទួលខុសត្រូវលើ រាល់ការខូចខាតណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោលជាពិសេស ឬដោយចៃដន្យ ដែលកើតឡើងទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះឡើយ។

៤. អ្នកចូលរួម យល់ព្រមដោយមិនអាចដកហូតវិញថា អ្នកចូលរួមយល់ព្រមសងសំណង និងធានាថា ធនាគារ ព្រីនស៍ នឹងទទួលបានសំណងគ្រប់ពេល លើរាល់ការបាត់បង់ ការខូចខាត កម្រៃសេវា កម្រៃសេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ និងរាល់វិបាកដែលកើតឡើងលើ ធនាគារ ព្រីនស៍ ឬបានទទួលរងដោយ ធនាគារ ព្រីនស៍ ចំពោះការទាមទារ ឬបណ្តឹងណាមួយដែលធ្វើឡើងដោយអ្នកចូលរួម ឬភាគីទីបីដែលកើតឡើង ឬទាក់ទងនឹងបញ្ញត្តិដែលមានចែងក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

៥. ក្នុងករណីមានការឆបោក ឬក្លែងបន្លំដែលប្រព្រឹត្តដោយ ឬមានពាក់ព័ន្ធនឹងអ្នកចូលរួមទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ អ្នកចូលរួមរូបនោះនឹងបាត់បង់សិទ្ធិចូលរួមកម្មវិធីលើកទឹកចិត្តនេះ។ អ្នកចូលរួមត្រូវប្រគល់មកវិញជូន ធនាគារ ព្រីនស៍ នូវរាល់ការផ្តល់ជូនដែលខ្លួនបានទទួលពី ធនាគារ ព្រីនស៍ តាមរយៈកម្មវិធីលើកទឹកចិត្តនេះ (ប្រសិនបើមាន) និងត្រូវសងសំណងការខូចខាតផ្សេងៗ ទៅតាមបញ្ញត្តិច្បាប់ជាធរមាន។ ក្នុងករណីនេះ ធនាគារ ព្រីនស៍ រក្សាសិទ្ធិក្នុងការចាត់វិធានការចាំបាច់ទៅតាមផ្លូវច្បាប់ចំពោះករណីឆបោក ឬក្លែងបន្លំនេះ។

៦. ធនាគារ ព្រីនស៍ រក្សាសិទ្ធិគ្រប់យ៉ាង ក្នុងការធ្វើវិសោធនកម្មលើបញ្ញត្តិនិងលក្ខខណ្ឌនេះ ពន្យាពេលបន្ថែមរយៈពេល ឬលុបចោលកម្មវិធីលើកចិត្តនេះ និង/ឬការផ្តល់ជូនដែលផ្តល់ជូន នៅពេលណាមួយក្នុងរយៈពេលកម្មវិធីលើកទឹកចិត្តដោយមិនមានការទទួលខុសត្រូវ តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារ ព្រីនស៍ ដោយគ្រាន់តែផ្តល់ការជូនដំណឹងពីការផ្លាស់ប្តូរ នៅលើគេហទំព័រផ្លូវការ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងទៀតរបស់ ធនាគារ ព្រីនស៍។

៧. បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយបញ្ញត្តិច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតឡើង ឬទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ នឹងត្រូវបានដោះស្រាយ ដោយអនុលោមតាមគោលនយោបាយដោះស្រាយបណ្ដឹងអតិថិជនរបស់ ធនាគារ ព្រីនស៍ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។